**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករមូលបត្រកម្ពុជា**

លេខ: ០០៥/២១ ន.ម.ក./គ.លា.ន.

ថ្ងៃ ព្រហស្បតិ៍ ១១ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២១

# គោលការណ៍ណែនាំ
# ស្តីពី
# មហាសន្និបាតភាគហ៊ុនិក
# សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ

* * * * *

យោងតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ប្រកាសលេខ ០១១/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ប្រកាសលេខ០០៩/១០ គ.ម.ក./ប្រ.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងដើម្បីជួយសម្រួលដល់ការយល់ដឹង និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម និយ័តករមូលបត្រកម្ពុជា(ន.ម.ក.) សូមចេញគោលការណ៍ណែនាំស្តីពី "មហាសន្និបាតភាគហ៊ុនិកសម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ" ដើម្បីឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតអនុវត្តក្នុងការរៀបចំមហាសន្និបាតភាគហ៊ុនិកដែលមានខ្លឹមសារដូចតទៅ÷

## I. គោលការណ៍ក្នុងការរៀបចំមហាសន្និបាតភាគហ៊ុនិក

### ក. ការសម្រេចរៀបចំមហាសន្និបាតភាគហ៊ុនិក

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវរៀបចំមហាសន្និបាតភាគហ៊ុនិកប្រចាំឆ្នាំ ដោយមិនត្រូវលើសពីរយៈពេល ៦(ប្រាំមួយ) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំជាប់ពន្ធនីមួយៗ។ បុគ្គលចុះបញ្ជីលក់មូលបត្រអាចរៀបចំមហាសន្និបាតវិសាមញ្ញរបស់ភាគហ៊ុនិកនៅពេលណាមួយបានតាមការចាំបាច់។

អាសយដ្ឋាន: អគារ 168F ផ្លូវ 598 សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ-កម្ពុជា
Address: Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

បុគ្គលចុះបញ្ជីលក់មូលបត្រអាចរៀបចំមហាសន្និបាតភាគហ៊ុនិកបាន តាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬតាមសំណើរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលប្រមូលផ្ដុំចាប់ពី ៥១% (ហាសិបមួយភាគរយ) ឡើងទៅនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។

នៅពេលទទួលបានលិខិតស្នើសុំរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលប្រមូលផ្ដុំចាប់ពី៥១% (ហាសិបមួយភាគរយ) ឡើងទៅនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប ប្រធានក្រុមប្រឹក្សាភិបាល ឬសមាជិកក្រុមប្រឹក្សាភិបាលយ៉ាងតិច ១/៣ (មួយភាគបី) ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលដើម្បីពិភាក្សាលើការរៀបចំមហាសន្និបាតភាគហ៊ុនិក ហើយក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំមហាសន្និបាតភាគហ៊ុនិកដើម្បីពិភាក្សាលើរបៀបវារៈដែលមានក្នុងលិខិតស្នើសុំរបស់ភាគហ៊ុនិកនោះ។

ប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានកោះប្រជុំមហាសន្និបាតភាគហ៊ុនិកក្នុងរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតស្នើសុំរបស់ភាគហ៊ុនិក ភាគហ៊ុនិកណាមួយដែលបានចុះហត្ថលេខាលើលិខិតស្នើសុំ អាចកោះប្រជុំមហាសន្និបាតភាគហ៊ុនិកបាន។

លិខិតស្នើសុំកោះប្រជុំមហាសន្និបាតភាគហ៊ុនិកដែលត្រូវបានស្នើឡើងភាគហ៊ុនិកត្រូវកំណត់÷

-ពេលវេលា និងរបៀបវារៈសម្រាប់មហាសន្និបាតភាគហ៊ុនិក

-សេចក្ដីពន្យល់គោលបំណងនៃការស្នើសុំកោះប្រជុំមហាសន្និបាតភាគហ៊ុនិក ដោយពន្យល់តាមរបៀបវារៈនីមួយៗ

-អត្តសញ្ញាណនៃភាគហ៊ុនិកដែលបានស្នើសុំ ដូចជា ឈ្មោះ លេខអត្តសញ្ញាណវិនិយោគិន ចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោត

-ហត្ថលេខារបស់ភាគហ៊ុនិកម្នាក់ ឬច្រើននាក់។

**ខ. ការចូលរួមមហាសន្និបាតភាគហ៊ុនិក**

ភាគហ៊ុនិកអាចចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ។ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវរៀបចំទម្រង់បែបបទសម្រាប់អាណត្តិគាហកៈ ដោយបញ្ជាក់ពីចំនួនភាគហ៊ុនដែលភាគហ៊ុនិកកាន់កាប់ អត្តសញ្ញាណរបស់អាណត្តិទាយក និងអាណត្តិគាហកៈ កាលបរិច្ឆេទដែលកំណត់អំពីសុពលភាពនៃសិទ្ធិតំណាង និងការកំណត់សិទ្ធិដែលអាណត្តិគាហកៈទទួលជាដើម។

**គ. ទីតាំង**

មហាសន្និបាតភាគហ៊ុនិកត្រូវរៀបចំនៅទីស្នាក់ការរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ឬទីកន្លែងណាមួយដែលមានលក្ខណៈសមស្រប និងមានភាពងាយស្រួលដល់ភាគហ៊ុនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មហាសន្និបាតភាគហ៊ុនិកអាចធ្វើឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែមានការយល់ព្រមពីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតទាំងអស់។

### ឃ. កូរ៉ុម

កូរ៉ុមសម្រាប់បើកមហាសន្និបាតភាគហ៊ុនិកត្រូវអនុវត្តស្របតាមលក្ខន្តិកៈរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។ ករណីលក្ខន្តិកៈរបស់បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានកំណត់អំពីកូរ៉ុមទេ មហាសន្និបាតភាគហ៊ុនិកអាចដំណើរការទៅបាន លុះត្រាតែមានវត្តមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រមូលផ្តុំចំនួនច្រើនជាង ៥០ (ហាសិប) ភាគរយនៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុបដែលមានវត្តមានដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ។

ករណីមិនគ្រប់កូរ៉ុម បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវកោះប្រជុំមហាសន្និបាតភាគហ៊ុនិកជាថ្មីមិនឱ្យលើសពីរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃមហាសន្និបាតភាគហ៊ុនិកលើកទី១។ កូរ៉ុមសម្រាប់មហាសន្និបាតភាគហ៊ុនិកជាលើកទី ២ នេះ អាចរៀបចំបានដោយមានវត្តមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតប្រមូលផ្តុំយ៉ាងតិច ១/៣(មួយភាគបី) នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប។ ករណីនេះ បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវជូនដំណឹងជាថ្មីដល់ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក អំពីកាលបរិច្ឆេទថ្មីនៃមហាសន្និបាតភាគហ៊ុនិកក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទនៃការរៀបចំមហាសន្និបាតភាគហ៊ុនិកជាលើកទី២។

ករណីមិនគ្រប់កូរ៉ុមសម្រាប់មហាសន្និបាតភាគហ៊ុនិកជាលើកទី ២ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវកោះប្រជុំមហាសន្និបាតភាគហ៊ុនិកជាថ្មីម្តងទៀតមិនឱ្យលើសពីរយៈពេល ២០(ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃមហាសន្និបាតភាគហ៊ុនិកជាលើកទី២។ ករណីនេះ បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវជូនដំណឹងអំពីកាលបរិច្ឆេទថ្មីនៃមហាសន្និបាតភាគហ៊ុនិកជាលើកទី ៣ ដល់ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិក ក្នុងរយៈពេលយ៉ាងតិច ១០(ដប់) ថ្ងៃ មុនកាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិកជាលើកទី៣។ កូរ៉ុមសម្រាប់មហាសន្និបាតភាគហ៊ុនិកជាលើកទី ៣ អាចរៀបចំបានដោយផ្អែកលើវត្តមានជាក់ស្តែងរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត។

ករណីកូរ៉ុមមិនគ្រប់ចំនួនក្នុងពេលបើកមហាសន្និបាត ការកោះប្រជុំមហាសន្និបាតជាថ្មីមិនត្រូវបានអនុញ្ញាតឱ្យពិភាក្សាលើរបៀបវារៈថ្មី និងមិនអាចសម្រេចទៅលើរបៀបវារៈទាំងឡាយណាដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចពិសេសឡើយ។

### ង. របៀបវារៈនៃមហាសន្និបាតភាគហ៊ុនិក

មហាសន្និបាតភាគហ៊ុនិកធ្វើការពិនិត្យសម្រេចលើរបៀបវារៈសំខាន់ៗដូចខាងក្រោម លើកលែងតែមានការកំណត់នៅក្នុងលក្ខន្តិកៈរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ÷

- ការកែប្រែឬលុបចោលលក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- ការជ្រើសរើសផ្លាស់ប្តូរ ឬដកហូតតំណែងជាអភិបាល
- ការទទួលកាន់កាប់បន្តរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នានិងការទិញយក
- ការទិញមូលបត្រកម្មសិទ្ធិមកវិញ
- ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជីក្រុមហ៊ុន
- ការបែងចែកភាគលាភ
- ការបោះផ្សាយលក់មូលបត្របន្ថែម
- ការកំណត់គោលនយោបាយស្តីពីលាភការឬប្រាក់បំណាច់សម្រាប់អភិបាល
- ការរាយការណ៍ពីផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ការរាយការណ៍ពីលទ្ធផលការងារប្រចាំឆ្នាំនិងបញ្ហាប្រឈមនានាដែលអាចនឹងកើតមាន
- របៀបវារៈផ្សេងទៀតដែលបានកំណត់ដោយលក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

នៅក្នុងរបៀបវារៈនៃមហាសន្និបាតភាគហ៊ុនិក បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវកំណត់ឱ្យមានរយៈពេលសមស្របសម្រាប់អនុញ្ញាតឱ្យភាគហ៊ុនិកអាចលើកឡើងនូវសំណួរ និងយោបល់ ព្រមទាំងសំណូមពរផ្សេងៗនៅក្នុងមហាសន្និបាតភាគហ៊ុនិក។

ច. សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក

សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិកមាន ២ (ពីរ) ប្រភេទគឺសេចក្តីសម្រេចសាមញ្ញ និងសេចក្តីសម្រេចពិសេស។

លក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវកំណត់អំពីចំនួនសំឡេងគាំទ្ររបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិក ដើម្បីអនុម័តនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ ករណីលក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានចែងបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវអនុវត្តដូចខាងក្រោម÷

ចំពោះសេចក្តីសម្រេចសាមញ្ញត្រូវអនុម័តដោយសំឡេងបោះឆ្នោតគាំទ្រច្រើនជាង ៥០ (ហាសិប) ភាគរយនៃចំនួនសំឡេងបោះឆ្នោតសរុបរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិក។

ចំពោះសេចក្តីសម្រេចពិសេសត្រូវអនុម័តដោយសំឡេងបោះឆ្នោតគាំទ្រភាគច្រើន ២/៣ (ពីរភាគបី) នៃចំនួនសំឡេងបោះឆ្នោតសរុបរបស់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតដែលមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិក។

សេចក្តីសម្រេចពិសេសមានដូចខាងក្រោម÷

- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
- ការប្រែប្រួលដើមទុនចុះបញ្ជី
- ការទទួលកាន់កាប់បន្តរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ
- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក
- ការរំលាយក្រុមហ៊ុន និងការជម្រះបញ្ជីក្រុមហ៊ុន
- ការទិញមូលបត្រកម្មសិទ្ធិមកវិញ
- ករណីផ្សេងទៀតដូចមានកំណត់នៅក្នុងលក្ខន្តិកៈក្រុមហ៊ុនរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

## II. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុនិក

### ក. កិច្ចដំណើរការមុនមហាសន្និបាតភាគហ៊ុនិក

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពការងារ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្កើតគណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកដែលដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល ឬបុគ្គលតំណាង។

១.បន្ទាប់ពីមានការសម្រេចរៀបចំមហាសន្និបាតភាគហ៊ុនិក បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្សព្វផ្សាយជាសាធារណៈភ្លាមឱ្យស្របទៅតាមប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម។

២.ក្រុមប្រឹក្សាភិបាលដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវរៀបចំបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក ដែលត្រូវបានកំណត់យកក្នុងរយៈពេលយ៉ាងតិច ២០ថ្ងៃ និងយ៉ាងយូរ ៥០ថ្ងៃ មុនកាលបរិច្ឆេទរៀបចំមហាសន្និបាតភាគហ៊ុនិក។ បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រត្រូវពន្យល់ដល់ភាគហ៊ុនិកឱ្យបានច្បាស់លាស់ថា÷

-បញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក គឺជាបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការដែលបានមកពីបញ្ជីឈ្មោះភាគហ៊ុនិកដែលរៀបចំឡើង ២(ពីរ) ថ្ងៃ នៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទកំណត់ទុក។

-ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធិរបស់ខ្លួន ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទកំណត់ទុក ឬនៅកាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) នៅតែមានសិទ្ធិចូលរួមនិងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក។

-ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធិ ១ (មួយ) ថ្ងៃនៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទកំណត់ទុក ឬនៅកាលបរិច្ឆេទអិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) មិនមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក និងបោះឆ្នោតឡើយ។

៣.បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវជូនដំណឹងអំពីការរៀបចំមហាសន្និបាតភាគហ៊ុនិកដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីតាំង និងរបៀបវារៈប្រជុំសម្រាប់មហាសន្និបាតភាគហ៊ុនិក ហើយត្រូវភ្ជាប់មកជាមួយលិខិតអញ្ជើញ ទម្រង់អាណត្តិគាហកៈ របៀបវារៈប្រជុំ និងឯកសារពាក់ព័ន្ធ

នឹងរបៀបវារៈដល់ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិចូលរួមក្នុងមហាសន្និបាតភាគហ៊ុនិក ក្នុងរយៈពេលយ៉ាងតិច ២០ (ម្ភៃ)ថ្ងៃ មុនកាលបរិច្ឆេទរៀបចំមហាសន្និបាតភាគហ៊ុនិក។

**ខ. កិច្ចដំណើរការអំឡុងពេលមហាសន្និបាតភាគហ៊ុនិក**

១.ប្រធានក្រុមប្រឹក្សាភិបាលត្រូវដឹកនាំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់ ឬអាចចាត់តាំងអភិបាលណាមួយឱ្យដឹកនាំប្រជុំជំនួស។

២.ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការមហាសន្និបាតភាគហ៊ុនិក គណៈកម្មការរៀបចំមហាសន្និបាតភាគហ៊ុនិកគប្បីបង្កើតអនុគណៈកម្មការតាមការចាំបាច់ដូចជា អនុគណៈកម្មការត្រួតពិនិត្យវត្តមាន អនុគណៈកម្មការរៀបចំកំណត់ត្រាមហាសន្និបាតភាគហ៊ុនិកដែលមានលេខាធិការក្រុមហ៊ុនជាប្រធានអនុគណៈកម្មការរៀបចំការបោះឆ្នោត និងអនុគណៈកម្មការផ្សេងទៀតតាមការចាំបាច់។

៣.អនុគណៈកម្មការត្រួតពិនិត្យវត្តមានត្រូវរាយការណ៍ជូនមហាសន្និបាតភាគហ៊ុនិកអំពីវត្តមានភាគហ៊ុនិកដែលបានចុះឈ្មោះចូលរួម និងបញ្ជាក់អំពីកូរ៉ុមដើម្បីអាចឱ្យមហាសន្និបាតភាគហ៊ុនិកដំណើរការបាន។ ករណីគ្រប់កូរ៉ុម ប្រធានអង្គប្រជុំត្រូវប្រកាសបើកជាផ្លូវការនូវមហាសន្និបាតភាគហ៊ុនិក។ ករណីមិនគ្រប់កូរ៉ុម ប្រធានអង្គប្រជុំត្រូវប្រកាសពន្យារពេលមហាសន្និបាតភាគហ៊ុនិក។

៤.ករណីកិច្ចដំណើរការមហាសន្និបាតភាគហ៊ុនិកមានរបៀបវារៈដែលតម្រូវឱ្យមានការបោះឆ្នោត អនុគណៈកម្មការរៀបចំការបោះឆ្នោតត្រូវរៀបចំនីតិវិធីនៃការបោះឆ្នោត ដើម្បីធានាបាននូវតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។

៥.ករណីកិច្ចដំណើរការមហាសន្និបាតភាគហ៊ុនិកមិនអាចបញ្ចប់បាននូវរាល់របៀបវារៈដែលបានកំណត់ ប្រធានអង្គប្រជុំត្រូវប្រកាសកំណត់កាលបរិច្ឆេទសមស្របណាមួយ ដើម្បីបន្តប្រជុំបញ្ចប់នូវរបៀបវារៈដែលនៅសេសសល់។ ករណីកាលបរិច្ឆេទប្រជុំបន្តលើសពីរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃបញ្ចប់មហាសន្និបាតភាគហ៊ុនិកលើកមុន បុគ្គលចុះបញ្ជីលក់មូលបត្រដោយមានជំនួយពីភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ត្រូវជូនដំណឹងដល់ភាគហ៊ុនិកអំពីកាលបរិច្ឆេទនៃមហាសន្និបាតភាគហ៊ុនិកបន្តនោះ។

៦.មុនប្រកាសបិទមហាសន្និបាតភាគហ៊ុនិក ប្រធានអង្គប្រជុំត្រូវប្រកាសលទ្ធផលកិច្ចប្រជុំដោយធ្វើការបូកសរុបលទ្ធផលដែលមហាសន្និបាតភាគហ៊ុនិកបានសម្រេច។

**គ. កិច្ចដំណើរការក្រោយមហាសន្និបាតភាគហ៊ុនិក**

១.ក្រោយបញ្ចប់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក អនុគណៈកម្មការរៀបចំកំណត់ត្រាមហាសន្និបាតភាគហ៊ុនិកត្រូវរៀបចំភ្លាមនូវសេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ហើយបុគ្គលចុះបញ្ជីលក់មូលបត្រត្រូវប្រកាសផ្សព្វផ្សាយជាសាធារណៈភ្លាម ដោយអនុលោមតាមប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម។

២.អនុគណៈកម្មការរៀបចំកំណត់ត្រាមហាសន្និបាតភាគហ៊ុនិក ត្រូវចាត់ចែងរៀបចំកំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកដោយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការរៀបចំកំណត់ត្រាមហាសន្និបាតភាគហ៊ុនិក និងប្រធានអង្គប្រជុំ។

៣.បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្ដល់កំណត់ហេតុកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកជូន ន.ម.ក. ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបញ្ចប់កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក ដូចមានក្នុងប្រកាសស្ដីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**និយ័តករមូលបត្រកម្ពុជា**